# I ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ . អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៤

### អនុក្រឹត្យលេខ ០២ អនក្រ ស្តីពីការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះ អន្តរក្រសួងទប់ស្កាត់បទល្មើសព្រៃឈើ . បទល្មើសនេសាទ . បទល្មើស កាប់ដើមកៅស៊ូ និង ដឹកជញ្ជូនជ័រកៅស៊ូ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីប្រកាស នៃ រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា លេខ ០៣ សប្រក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការទប់ស្កាត់បទល្មើសវិស័យកៅស៊ូ
- យោងសារាចររាជរដ្ឋាភិបាលកម្ពុជា លេខ ១៥ ស.រ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការទប់ស្កាត់បទល្មើសនេសាទ និង បទល្មើសព្រៃឈើ
- តាមសំណើរបស់មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

ប្រការ ១ ៖ បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងដែលមានសមាសភាពដូចខាងក្រោម ÷

១ - ឯកឧត្តម កៅ សេងហួរ រដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ប្រធាន

២ - ឯកឧត្តម ខង់ សាវឿន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣ - ឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៤ - ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន សមាជិក

៥ - ឯកឧត្តម លូ ឡាយស្រេង អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៦ - ឯកឧត្តម ជា ប៉េងឈាង អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

**ប្រការ ២ :** គណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងមានភារកិច្ចដូចតទៅ ÷

១ - លើកវិធានការណ៍ និង ចាត់ចែងកំលាំងទប់ស្កាត់ និង បង្ក្រាបបទល្មើសទាំងឡាយដូចមានចែងខាងលើ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២ - តាមដាន និង ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និង បទបញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងវិស័យ ព្រៃឈើ - នេសាទ - កៅស៊ូ

៣ - រាយការណ៍ និង វាយតំលៃសភាពការណ៍ និង លទ្ធផលនៃការបង្ក្រាបបទល្មើសនេសាទ - បទល្មើសព្រៃឈើ និង ការកាប់ដើមកៅស៊ូ ដឹកជញ្ជូនជ័រកៅស៊ូខុសច្បាប់ ជូនរាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ ៣ :** គណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងនេះ មានលេខាធិការដ្ឋានជាសេនាធិការ ដើម្បីជួយការងារក្នុងការអនុវត្តភារកិច្ចជាក់ស្តែង ក្នុងការរាល់ឧបសគ្គទប់ស្កាត់បទល្មើសទាំងឡាយខាងវិស័យព្រៃឈើ - នេសាទ - កៅស៊ូ ។

សមាសភាពនៃលេខាធិការដ្ឋានមានដូចខាងក្រោមនេះ ÷

១ - ឯកឧត្តម ម៉ៃ សំអឿន អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ប្រធាន

២ - ឯកឧត្តម សរ ឫ នាយកទីចាត់ការគយ និង រដ្ឋាករ សមាជិក

៣ - ឧត្តមសេនីយត្រី ពៅ សិទ្ធិ ក្រសួងមហាផ្ទៃ សមាជិក

៤ - ឧត្តមសេនីយទោ ភួង ប៊ុនធឿន កងរាជអាវុធហត្ថ សមាជិក

៥ - ឧត្តមសេនីយឯក យឹម សារី នាយកកស្តុភារអគ្គសេនាធិការដ្ឋាន សមាជិក

៦ - លោក តេង ឡាវ អគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក

៧ - លោក លី ផល្លា នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស សមាជិក

៨ - លោក ប៉ូ សេងជី នាយកដ្ឋានជលផល សមាជិក

៩ - លោក ចាន់ ឃន នាយកដ្ឋានរុក្ខាប្រមាញ់ សមាជិក

**ប្រការ ៤ :** សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង លេខាធិការដ្ឋាន ត្រូវចូលរួមធ្វើការងារតាមការ

អញ្ជើញរបស់ប្រធាន ។

ប្រការ ៥ : ក្រសួង - ស្ថាប័ន និង ខេត្ត - ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវរួមសហការជាមួយក្រុមលេខាធិការដ្ឋាន នៃ គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងករណីដែលក្រុមលេខាធិការដ្ឋានបើកសំណូមពរ ។

ប្រការ ៦ : គណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងនេះ មានទីស្នាក់អចិន្ត្រៃយ៍នៅក្រសួងកសិកម្មរុក្ខា - ប្រមាញ់ និងនេសាទ ព្រមទាំងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ៧ : ត្រូវបានជូនប្រាក់រង្វាន់លើកទឹកចិត្តចំនួន ១០ ភាគរយ លើទឹកប្រាក់សរុប ដែលពិន័យបាន ចំពោះផ្នែកជលផល ឬ រុក្ខាប្រមាញ់ ។ ចំពោះកៅស៊ូ ត្រូវបានឧបត្ថម្ភជាប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ១០ ភាគរយ លើទឹកប្រាក់ដែលបានពីការលក់ជ័រកៅស៊ូ ឬ ដើមកៅស៊ូ ។

ប្រការ ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធ និង គ្រប់ខេត្ត - ក្រុង និង សាមីខ្លួនមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និងត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

※ ※ ※ ※